ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២៥៥៤ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៥

# សេចក្តីណែនាំ
## ស្តីពី
## ការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស តាមរបបម៉ៅការ (ទម្រង់ ១០២)

ដើម្បីឲ្យដំណើរការនៃការចុះបញ្ជីពន្ធដារ ក៏ដូចជាការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដំណើរការទៅកាន់តែរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់ថែមទៀត ជាពិសេស កាត់បន្ថយឲ្យបានជាអតិបរមានូវភាពខុសឆ្គងក្នុងការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារតាមរបបម៉ៅការ (ទម្រង់ ១០២) អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំលម្អិតដូចខាងក្រោម ÷

I. **ព័ត៌មានអាជីវកម្មដ្ឋាន**

- **ឈ្មោះអាជីវកម្មដ្ឋានជាភាសាខ្មែរ និងអក្សរឡាតាំង**
  - សូមបំពេញឈ្មោះ ជាអក្សរខ្មែរ និងជាអក្សរឡាតាំង អក្សរធំ (CAPITAL LETTERS)

***បញ្ជាក់÷** ប្រសិនបើ គ្មានឈ្មោះអាជីវកម្មដ្ឋាន សូមបំពេញថា "គ្មាន"។

**១.អាសយដ្ឋានរបស់អាជីវកម្ម**

- **សូមជ្រើសរើសការបំពេញអាសយដ្ឋានរបស់អាជីវកម្ម**
  - ប្រសិនបើអាជីវកម្មដ្ឋានលោក/លោកស្រីនៅក្នុងផ្សារ សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐សម្រាប់អាជីវកម្មក្នុងផ្សារ រួចហើយសូមបំពេញអាសយដ្ឋាន និងព័ត៌មានសម្រាប់ទំនាក់ទំនងដូចខាងក្រោម÷
    - ឈ្មោះផ្សារ - តូបលេខ - ច្រកលេខ
    - សារអេឡិកត្រូនិក - ប្រអប់សំបុត្រអេឡិកត្រូនិក - ទូរស័ព្ទចល័ត - ទូរស័ព្ទលើតុ - ទូរសារ (បើមាន)
  - ប្រសិនបើអាជីវកម្មដ្ឋានលោក/លោកស្រីនៅផ្ទះ សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐សម្រាប់អាជីវកម្មតាមផ្ទះ រួចហើយសូមបំពេញអាសយដ្ឋាន និងព័ត៌មានសម្រាប់ទំនាក់ទំនងដូចខាងក្រោម÷
    - ផ្ទះលេខ/អគារ - ផ្លូវ - ភូមិ - ឃុំ/សង្កាត់ - ក្រុង/ស្រុក/ខណ្ឌ - ខេត្ត/រាជធានី
    - សារអេឡិកត្រូនិក - ប្រអប់សំបុត្រអេឡិកត្រូនិក - ទូរស័ព្ទចល័ត - ទូរស័ព្ទលើតុ - ទូរសារ (បើមាន)

***បញ្ជាក់÷** ប្រសិនបើទីកន្លែងប្រកបអាជីវកម្មនៅតាមផ្ទះ ហើយគ្មានលេខផ្ទះ ឬលេខផ្លូវ សូមផ្តល់គំនូសប្លង់បង្ហាញទីតាំង និងផ្លូវព្រមទាំងភ្ជាប់រូបថតអគារដែលស្ថិតក្នុងទីតាំងមកជាមួយផង។ ក្នុងករណីលេខផ្ទះ/ឈ្មោះអគារ ឬលេខផ្លូវ ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ រាជធានី/ខេត្ត មានការផ្លាស់ប្តូរ ដោយស្ថាប័នមានសមត្ថកិច្ចសូមបំពេញឈ្មោះដែលបានកែប្រែដោយបញ្ជាក់បន្ថែមអំពីឈ្មោះចាស់ផងដែរ។

- **តើអចលនទ្រព្យដែលមានអាសយដ្ឋានខាងលើនេះជាកម្មសិទ្ធិរបស់សហគ្រាសផ្ទាល់ ឬជួល?**
  - ប្រសិនបើជាកម្មសិទ្ធិ សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐កម្មសិទ្ធិ។ សូមភ្ជាប់មកជាមួយនូវប័ណ្ណកម្មសិទ្ធិអចលនទ្រព្យ ឬឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់បានថាពិតជាកម្មសិទ្ធិផ្ទាល់របស់សហគ្រាស (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីមន្ត្រីពន្ធដារ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ)។

Collection by VCAT Professional Consultant



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

○ ប្រសិនបើជួល សូមគូសសញ្ញា ✓ ក្នុងប្រអប់ □ជួល។ សូមភ្ជាប់មកជាមួយនូវកិច្ចសន្យាជួលទីតាំង ឬលិខិតអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងដោយមិនគិតថ្លៃឈ្នួល (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីមន្ត្រីពន្ធដារ ឬក្រសួងស្ថាប័នពាក់ព័ន្ធ)។

○ ប្រសិនបើអចលនទ្រព្យនោះគ្មានលេខអត្តសញ្ញាណកម្មអចលនទ្រព្យ សូមគូសសញ្ញា ✓ ក្នុងប្រអប់ □គ្មាន។

○ ប្រសិនបើអចលនទ្រព្យនោះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យ សូមគូសសញ្ញា ✓ ក្នុងប្រអប់ □មាន និងបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ១១ខ្ទង់លើលិខិតប្រកាសពន្ធអចលនទ្រព្យប្រចាំឆ្នាំ ដែលចេញដោយរដ្ឋបាលសារពើពន្ធ។ សូមភ្ជាប់លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ ប្រសិនបើអចលនទ្រព្យខាងលើស្ថិតនៅក្នុងដែនដីរដ្ឋបាលក្រុង/ស្រុក ឬរាជធានី/ខេត្ត ដែលជាប់ពន្ធលើអចលនទ្រព្យ។

***បញ្ជាក់÷** រាល់អចលនទ្រព្យរបស់អាជីវកម្មដ្ឋាន ដែលត្រូវចុះបញ្ជីពន្ធដារ ហើយស្ថិតនៅក្នុង រាជធានី/ខេត្ត ដែលជាប់ពន្ធលើអចលនទ្រព្យត្រូវបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ១១ខ្ទង់ និងសូមភ្ជាប់នូវលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ។ ចំពោះអចលនទ្រព្យដែលមិនស្ថិតនៅក្នុងរាជធានី/ខេត្ត ហើយមិនជាប់ពន្ធលើអចលនទ្រព្យ អគ្គនាយកដ្ឋានមិនតម្រូវឱ្យបំពេញ និងភ្ជាប់នូវលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យឡើយ។

**២. សកម្មភាពអាជីវកម្ម**

- សូមបំពេញសកម្មភាពអាជីវកម្មរបស់សហគ្រាសជាភាសាខ្មែរ និងភាសាអង់គ្លេស។

**៣. ព័ត៌មានស្តីពីនិយោជិក**

- សូមបំពេញចំនួននិយោជិត (បុគ្គលិក ឬកម្មករ) និងប្រាក់ខែសរុបជាប្រាក់រៀល (បើមាន)

## II. ព័ត៌មានម្ចាស់អាជីវកម្ម

- **ឈ្មោះជាភាសាខ្មែរ និងអក្សរឡាតាំង លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន**

  - សូមបំពេញព័ត៌មានលម្អិតដូចជា÷ ឈ្មោះជាអក្សរខ្មែរ និងជាអក្សរឡាតាំង អក្សរធំ (CAPITAL LETTERS) និងសូមគូសសញ្ញា ✓ ក្នុងប្រអប់ □លេខអត្តសញ្ញាណប័ណ្ណ ប្រសិនបើប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬគូសសញ្ញា ✓ ក្នុងប្រអប់ □ លេខលិខិតឆ្លងដែន ប្រសិនបើប្រើលិខិតឆ្លងដែន ហើយសូមបំពេញលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលេខលិខិតឆ្លងដែន។
  - សូមភ្ជាប់រូបថតបច្ចុប្បន្ន (ពណ៌ធម្មជាតិ រូបថតឃើញស្លឹកត្រចៀកសងខាង ត្រង់ខ្លួន មិនពាក់វ៉ែនតា) មិនលើសពី ៣ខែ ទំហំ ៣៥ × ៤៥ មីលីម៉ែត្រ ចំនួន ២សន្លឹក និងមានបញ្ជាក់ឈ្មោះ និងចុះហត្ថលេខាដោយម្ចាស់រូបថតនៅខាងខ្នងនៃរូបថត។

**១. អាសយដ្ឋានរបស់ម្ចាស់អាជីវកម្ម**

- **តើអាសយដ្ឋានរបស់ម្ចាស់អាជីវកម្មដូចអាសយដ្ឋានអាជីវកម្មខាងលើដែរឬទេ?**

  - ប្រសិនបើដូច សូមគូសសញ្ញា ✓ ក្នុងប្រអប់ □ដូច បន្តការបំពេញនូវព័ត៌មានចំណុចទី III នៃទម្រង់ ១០២ នេះ។
  - ប្រសិនបើមិនដូច សូមគូសសញ្ញា ✓ ក្នុងប្រអប់ □មិនដូច ហើយសូមបំពេញព័ត៌មានតាមចំណុចនីមួយៗ និងសូមភ្ជាប់ឯកសារតម្រូវផ្សេងៗ ដែលមានលក្ខណៈដូចI-១. អាសយដ្ឋានរបស់អាជីវកម្មដ្ឋាន នៃសេចក្តីណែនាំនេះ។

## III. ការប៉ាន់ស្មានប្រាក់ចំណូល

ការប៉ាន់ស្មានប្រាក់ចំណូលជាប់ពន្ធ ត្រូវធ្វើឡើងដោយការពិភាក្សាគ្នារវាងអ្នកជាប់ពន្ធតាមរបបម៉ៅការ និងរដ្ឋបាលសារ

ពើពន្ធ ដូចនេះអ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវជូនដំណឹងមកសាខាពន្ធដារខេត្ត-ខណ្ឌ នៅពេលចាប់ផ្តើម ឬក្នុងរយៈពេល ១៥ថ្ងៃបន្ទាប់ពីប្រកបអាជីវកម្ម ដើម្បីឲ្យមន្ត្រីជំនាញកំណត់ប្រាក់ចំណូលជាប់ពន្ធ មុននឹងបំពេញនូវព័ត៌មានខាងក្រោមនេះ÷

**- អាករលើផលរបរ - អាករពិសេសលើទំនិញ - អាករពិសេសលើសេវាមួយចំនួន**

**- អាករបំភ្លឺសាធារណៈ - អាករលើការស្នាក់នៅ - ពន្ធផ្សេងៗ**

***បញ្ជាក់÷** រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រាក់ពន្ធត្រូវបង់ប្រចាំខែនីមួយៗ ដោយត្រូវគណនាប្រាក់ពន្ធប៉ាន់ស្មានសម្រាប់រយៈពេល ៣ខែ ៦ខែ ឬ១២ខែ ផ្អែកទៅតាមការចុះពិនិត្យផលរបរដល់ទីតាំងអាជីវកម្មដ្ឋានផ្ទាល់ ឬលើមូលដ្ឋានផ្សេងៗ ដែលបានពិភាក្សា និងឯកភាពគ្នារវាងមន្ត្រីជំនាញ និងអ្នកជាប់ពន្ធ។ អ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវរៀបចំខ្លួនឲ្យបានរួចរាល់ ដើម្បីក្លាយជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស នៅពេលដែលមានផលរបរដល់កម្រិតត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាស។

**- កាលបរិច្ឆេទ -ហត្ថលេខា ឬស្នាមមេដៃ - ឈ្មោះ - តួនាទី - លេខទូរស័ព្ទ**

- សូមបំពេញ កាលបរិច្ឆេទ និងចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ ឈ្មោះ តួនាទី លេខទូរស័ព្ទ របស់ម្ចាស់អាជីវកម្ម។

## IV. ការបង់ប្រាក់កម្រៃសេវាចុះបញ្ជី ឬធ្វើបច្ចុប្បន្នភាព

- តម្លៃសេវាចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ២០,០០០រៀល (ម្ភៃពាន់រៀល)

- តម្លៃសេវាធ្វើបច្ចុប្បន្នភាព និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ១០,០០០រៀល (ដប់ពាន់រៀល)

អ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវបង់ប្រាក់កម្រៃសេវានេះនៅរដ្ឋបាលសារពើពន្ធ ឬក៏បង់នៅធនាគារចូលទៅគណនីរបស់អគ្គនាយកដ្ឋានពន្ធដារដូចខាងក្រោម÷

- ឈ្មោះធនាគារ÷ ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ឈ្មោះគណនី ÷ អគ្គនាយកដ្ឋានពន្ធដារ/កម្រៃសេវាចុះបញ្ជីពន្ធ
- លេខគណនី ÷ 0001-01927915-1-5

សេចក្តីដូចបានណែនាំខាងលើ អគ្គនាយកដ្ឋានពន្ធដារ សូមស្នើលោក-លោកស្រី ដែលជាម្ចាស់អាជីវកម្មដ្ឋានអនុវត្តតាមសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**